# ជំពូកទី ៩

# សន្និដ្ឋាន និងអនុសាសន៍

Draft

Draft

# ជំពូកទី ៩
# សន្និដ្ឋាន និងអនុសាសន៍

## ៩.១ ការសន្និដ្ឋាន

គម្រោង ធ្វើអាជីវកម្មរ៉ែលោហៈរបស់ ក្រុមហ៊ុន **PHU YANG (CAMBODIA) Co., Ltd.** ជាគម្រោងដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើការវិនិយោគលើគម្រោង ធ្វើអាជីវកម្មរ៉ែលោហៈ ដែលជាការវិនិយោគមួយសមស្របបំផុតនៅលើទីកដីនៃតំបន់ភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។គម្រោងនេះបានវិនិយោគលើផ្ទៃដីសរុប ៨០០ហិកតា។ ផលិតផលដែលគ្រោងផលិតក្រុមហ៊ុននឹងធ្វើការផ្គត់ផ្គង់ចំពោះទីផ្សារទាំងក្នុងស្រុក និងនាំចេញទៅក្រៅប្រទេសទៅតាមតម្រូវការទីផ្សារ។ ដោយសារដំណើរការរបស់គម្រោងអាចនឹងបង្កនូវហេតុអវិជ្ជមានខ្លះៗចំពោះតំបន់ដែលគម្រោងតាំងនៅ ហេតុនេះគម្រោងបានរៀបចំអោយមានជារបាយការណ៍វាយតំលៃហេតុ ប៉ះពាល់បរិស្ថាន និងសង្គមពេញលេញឡើង ដើម្បីសិក្សាកំណត់ពីហេតុប៉ះពាល់ជាមុន។

ទីតាំងវិនិយោគលើគម្រោងធ្វើអាជីវកម្មរ៉ែលោហៈ ស្ថិតនៅក្នុងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលជាប់ពាក់ព័ន្ធជាមួយនឹងដីឃុំចំនួន ០១គឺ ឃុំភ្នំព្រឹក ដែលមានផ្ទៃដីវិនិយោគសរុប ៨០០ហិកតា។ក្រុមហ៊ុនវិនិយោគនេះមានម្ចាស់ភាគហ៊ុនចំនួន ០៥រូបគឺ (១) លោក លីន លុន ជាប្រធានក្រុមប្រឹក្សាភិបាល (២) លោក ប៊ុន ចាន់នី ជាអភិបាល (៣) លោកស្រី តៅ ភ៉ានី (៤) លោក អ៊ឹង ថៃអ៊ីតមិញ និង (៥) លោកស្រី CHU THI PHUONG DUNG ដែលមានដើមទុនចុះបញ្ជីសរុបចំនួន ២០.០០០.០០០ រៀល (ម្ភៃលានរៀល)។

ចំណាត់ថ្នាក់ទីជំរាលក្នុងតំបន់សិក្សាមានការប្រែប្រួលពី ០ ទៅ៩០ដឺក្រេ ដែលមានកំរិតទីជំរាលមធ្យម ១២,២៩ដឺក្រេ ដែលមាន Standard Deviation = ១៤.៨៦ Percent ។ កំរិតទីជំរាលត្រូវបានបែងចែកជា ០៤ចំណាត់ថ្នាក់ធំៗគឺៈ កំរិត ទីជំរាល ០-៥ដឺក្រេចំនួន ២៥៧ ហិកតា ត្រូវនឹង ៦៤,២៥៣% កំរិតទីជំរាល៥-២០ដឺក្រេ ចំនួន ៧២ ហិកតា ដែលត្រូវនឹង១៨% កំរិតទីជំរាល២០-៣០ដឺក្រេ ចំនួន៦១ ហិកតា ដែលត្រូវនឹង ១៥,២៥% និងកំរិតទីជំរាលធំជាង៣០ដឺក្រេចំនួន១០ហិកតាដែលត្រូវនឹង២,៥%នៃផ្ទៃដីសរុបរបស់គំរោង។

ចំណាត់ថ្នាក់ប្រភេទដីមានចំនួន ០២ប្រភេទគឺ ប្រភេទដី Basic Lithosols: មានទំហំផ្ទៃដី ៣៩៩ ហិកតា ស្មើនឹង ៩៩,៧៥% និងប្រភេទដីLatosols: មានទំហំផ្ទៃដី ០១ ហិកតា ស្មើនឹង ០,២៥% នៃផ្ទៃដីស្នើសុំសរុប។

ផ្អែកតាមការសិក្សាលើផែនទីគំរបព្រៃឆ្នាំ ២០០២ បានបង្ហាញថា តំបន់ដីសម្បទានស្នើសុំនេះមានប្រភេទព្រៃឈើចំនួន ០២ប្រភេទរួមមានព្រៃស្រោង ៩៩ ហិកតា និងដីគ្មានគំរបព្រៃ ៣០១ ហិកតា។

ចំពោះប្រភពទឹកនៅក្នុងតំបន់គម្រោង មានប្រព័ន្ធផ្លូវទឹកសំខាន់ ០១គឺ អូរព្រំដែន ដែលមានទំហំផ្ទៃដី ៣.៣៦៩,៥៣ ម៉ែត្រ ស្មើនឹង ១៥,៧៦% នៃប្រវែងអូរសរុបក្នុងទីតាំងគំរោង។អូរនេះហូរពីទិសខាងត្បូងទៅទិសខាងជើង ហើយអូរនេះរីងទឹកនៅរដូវប្រាំង។ចំងាយពីអូរព្រំដែនទៅទីតាំងគម្រោង ពីទិសខាងលិចទៅទិសខាងកើតមានចំងាយ ៧៦០ម៉ែត្រ។

យោងតាមលទ្ធផលនៃការចុះសិក្សាអង្កេតជាក់ស្តែងពី ស្ថានភាពធនធានព្រៃឈើនៅក្នុងតំបន់គំរោងមានតែដីចំការ និងដីលំនៅស្ថានរបស់ប្រជាពលរដ្ឋភាគច្រើន ចំណែកព្រៃពិតប្រាកដនៅក្នុងទីតាំងគំរោងបានបង្ហាញថាមិនមានធនធានព្រៃឈើ ដែលមានតំលៃខាងផ្នែកសេដ្ឋកិច្ចទេ ធនធានព្រៃឈើគឺមានតែនៅលើភ្នំប៉ុណ្ណោះដែលជា

Draft

ព្រៃរេចរិល ហើយភ្នំមួយចំនួនត្រូវបានកាប់រានយកដីធ្វើចំការជាបណ្តើរៗ។ចំពោះប្រភេទដើមឈើដែលមាននៅក្នុងតំបន់គម្រោងមានដូចជាដើមធ្នង់ កំរៀង ស្តុង សុក្រំ ស្រឡៅ ដែលមានអង្កត់ផ្ចិតតូចជាង១០សង់ទីម៉ែត្រ។ ទន្ទឹមនឹងនោះក៏មានការធ្វើអាជីវកម្មរ៉ែអោណាធិបតេយ្យជាច្រើនផងដែរដែលមានភ្ជាប់រូបភាពនិងចំណុចនិយាមការនៅក្នុង(ឧបសម្ព័ន្ធទី៣)។

ស្ថានភាពធនធានសេដ្ឋកិច្ច-សង្គមក្នុងតំបន់ស្នើសុំ ពុំសូវមានលក្ខណៈខុសប្លែកពីតំបន់ផ្សេងៗ ដែលមិនស្ថិតនៅឆ្ងាយពីតំបន់ប្រជុំជនប៉ុន្មានទេ។ ចំពោះមុខរបរសំខាន់របស់ប្រជាជនក្នុងតំបន់នោះគឺការធ្វើចំការ(ដាំពោត ដំឡូងមី និងសណ្តែក)។ ក្រៅពីនោះគឺប្រជាជនប្រកបរបរស៊ីឈ្នួលគេតាមចំការ ដើម្បីរកចំណូលមកផ្គត់ផ្គង់ជីវភាពគ្រួសារ។

ប្រភពទឹកសំខាន់សំរាប់ប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាជនគឺ ទឹកអណ្តូង និងទឹកភ្លៀង។ ឯទឹកអូរព្រំដែនគឺប្រើសំរាប់បោកគក់បន្តិចបន្តួច និងលាងសត្វពាហនៈ(អូរនេះរីងទឹកនៅរដូវប្រាំង)។

ប្រជាជនបានចំនួនច្រើននាំអោយតម្រូវការទឹកស្អាតសំរាប់ប្រើប្រាស់ក៏មានបរិមាណច្រើនដែរ ឯការបរិភោគទឹករបស់ប្រជាជនគឺពួកគាត់បានយកទឹកភ្លៀង រឺទឹកអណ្តូងដែលដាំពុះទៅច្រោះនឹងឧបករណ៍សំរាប់ចំពោះទឹក ដើម្បីសំលាប់មេរោគមុននឹងយកទៅបរិភោគ។ នេះបង្ហាញថាប្រជាជនមានការយល់ដឹងច្រើនពីបញ្ហាសុខភាព និងអនាម័យនៃការរស់នៅស្អាត។

គម្រោងស្នើសុំនេះមានជាប់ពាក់ព័ន្ធជាមួយនឹងការប្រើប្រាស់ដីរបស់ប្រជាជនភូមិភ្នំព្រឹក (ដីចំការ និងដីភូមិដ្ឋាន)មានទំហំប្រហែលជា ២៩២ ហិកតា និងមានការជាប់ពាក់ព័ន្ធជាមួយនឹងដីទ្រនាប់ដងអូរទំហំ ៥៩ ហិកតា។

តាមការវាយតំលៃជាបឋម គំរោងនេះនឹងបង្កហេតុប៉ះពាល់ដល់ធនធានមួយចំនួនដូចជា ធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម។ ផលប៉ះពាល់ចំពោះធនធានរូបសាស្ត្រមានដូចជា: ការប៉ះពាល់ដល់គុណភាពទឹកលើដី និងក្រោមដី ស្ថេរភាពនៃធនធានទឹកលើដី និងក្រោមដី។ ពាក់ព័ន្ធទៅនឹងធនធានជីវសាស្ត្រ វាមានការប៉ះពាល់ដល់ធនធានព្រៃឈើ និងសត្វព្រៃ ប្រសិនបើគ្មានការរក្សាទុកនូវតំបន់ដែលជាទីជំរករបស់វានោះទេ។

ចំពោះការប៉ះពាល់ដល់ការប្រើប្រាស់ដីចំការ និងដីភូមិដ្ឋានរបស់ប្រជាជន ដែលមានដីនៅក្នុងដី ដែលក្រុមហ៊ុនបានស្នើសុំនេះ គឺជាដីដែលមានការទទួលស្គាល់ស្របច្បាប់ពីអាជ្ញាធរក្នុងតំបន់។ ក្រៅពីនោះ គំរោងនេះក៏នឹងប៉ះពាល់ដល់ការប្រើប្រាស់ទឹក និងជីវភាពរស់នៅរបស់ពួកគាត់ប្រសិនណាប្រភពទឹកនានារងការបំពុល។

ទោះជាយ៉ាងណា វត្តមាននៃគំរោងវិនិយោគនេះ ក៏នឹងអាចផ្តល់មកវិញនូវផលប្រយោជន៍ ជាច្រើនដល់ប្រជាជនមូលដ្ឋាន និងប្រទេសជាតិទាំងមូលតាមរយៈ:

- ការបង្កើនអោយមានការងារធ្វើសម្រាប់ប្រជាជនពេញវ័យ និងប្រជាជនពេញវ័យ និងប្រជាជនស្ថិត នៅក្នុងក្រុមអាយុប្រជាជនសកម្ម
- អភិវឌ្ឍន៍ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ មានដូចជា ផ្លូវថ្នល់ អណ្តូងទឹក និងសាលារៀនជាដើម
- ជួយដល់ការអភិវឌ្ឍន៍ប្រទេសជាតិតាមរូបភាពផ្សេងៗ។ល។

ជារួមវត្តមានគំរោងនេះនឹងជួយដល់ការសំរេចបាននូវយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនប្រកបដោយលក្ខណៈជានិរន្តរភាព ក្នុងករណីដែលមានការសិក្សាអោយបានល្អត្រឹមត្រូវ និងការអនុវត្តតាមគោលការណ៍ណែនាំរបស់រដ្ឋាភិបាល។

## ៩.២ អនុសាសន៍

ដើម្បីជៀសវាងនូវបញ្ហាដូចបានបង្ហាញខាងលើនេះ ក្រុមហ៊ុនត្រូវអនុវត្តនូវវិធានការកាត់បន្ថយហេតុប៉ះពាល់មួយចំនួនរួមមាន:

-មិនត្រូវបង្ហូរសំណល់រាវ ដែលមានសារធាតុកករល្អក់ពីការធ្វើអាជីវកម្មរ៉ែលោហៈនៅក្នុងប្រភពទឹក និងអូរនានាដោយផ្ទាល់ទេដើម្បីជៀសវាងការប៉ះពាល់ដល់គុណភាពទឹក។

-ការរក្សាទុកផ្ទៃដីព្រៃសហគមន៍របស់ប្រជាពលរដ្ឋក្នុងតំបន់គម្រោង

-គ្រប់គ្រងសំណល់រឹង រាវ និងសំណល់ប្រេងម៉ាស៊ីនអោយបានត្រឹមត្រូវ ព្រមទាំង បង្កើនការអប់រំ ដល់បុគ្គលិកកម្មករអោយចេះថែរក្សាអនាម័យ និងបរិស្ថានល្អទាំងក្នុង និងក្រៅតំបន់គម្រោង និងការពារសុខភាពផ្ទាល់ខ្លួនអោយបានត្រឹមត្រូវ ព្រមទាំងរៀបចំអោយមានបន្ទប់ពិនិត្យសុខភាព និងផ្តល់ការព្យាបាល ប្រកបដោយប្រសិទ្ធភាព។

-កំណត់ពេលវេលាធ្វើការ ដោយជៀសវាងធ្វើការនៅពេលថ្ងៃត្រង់ និងពេលយប់ ព្រោះជាពេលវេលាសំរាករបស់ប្រជាជន និងបុគ្គលិក កម្មករគម្រោង។

-អប់រំណែនាំដល់បុគ្គលិក កម្មករគម្រោងអោយចេះគោរពច្បាប់ និងផ្លាកសញ្ញាចរាចរណ៍ និងបើកបរដោយយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់។

-ផ្តល់អាទិភាពខ្ពស់ដល់ប្រជាជននៅក្នុងតំបន់ អាចធ្វើជាបុគ្គលិក កម្មករនៅក្នុងតំបន់គម្រោងតាមសមត្ថភាពដែលមាន។

-ធ្វើការថែទាំ និងជួសជុលផ្លូវគមនាគមន៍នៅក្នុងតំបន់គម្រោងជាប្រចាំ ហើយត្រូវធានាថានឹងដាក់ផ្លូវទាំងនោះជាផ្លូវសាធារណៈ ដើម្បីអោយប្រជាជនអាចប្រើប្រាស់ផ្លូវនេះក្នុងការធ្វើដំណើរ និងប្រកបរបរចិញ្ចឹមជីវិតស្របច្បាប់របស់ពួកគាត់។

-ត្រូវដោះស្រាយអោយមានភាពត្រឹមត្រូវ និងសមស្របនូវរាល់ដីធ្លីរបស់ប្រជាជនដែលរងនូវការប៉ះពាល់។

-គ្រប់គ្រង និងទុកអាចម៍ដីរ៉ែ ដែលបានវែងរួចអោយបានត្រឹមត្រូវដើម្បីយកទៅលប់ក្នុងរណ្តៅដែលបានជីករួច និងត្រូវដាំដើមឈើដែលមានក្នុងតំបន់ឡើងវិញ។

ជារួមដើម្បីជៀសវាង ឬកាត់បន្ថយនូវហេតុប៉ះពាល់បរិស្ថាន និងសង្គមខាងលើ បន្ថែមពីលើការអនុវត្តនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ដោយគម្រោងផ្ទាល់ គម្រោងក៏ត្រូវអនុវត្តនូវផែនការគ្រប់គ្រងបរិស្ថាន ដោយមានកម្មវិធីត្រួតពិនិត្យជាប្រចាំដោយមានការសហការជាមួយមន្ត្រីជំនាញនៃក្រសួងបរិស្ថាន មន្ត្រីមន្ទីរបរិស្ថានខេត្តបាត់ដំបង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តបាត់ដំបង មន្ទីរធនធានទឹក និងឧតុនិយមខេត្តបាត់ដំបង មន្ទីរកសិកម្មខេត្តបាត់ដំបង មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបាត់ដំបង ខណ្ឌរដ្ឋបាលព្រៃឈើបាត់ដំបង និងខណ្ឌរដ្ឋបាលជលផលបាត់ដំបង អាជ្ញាធរខេត្ត ស្រុក ឃុំ និងតំណាងសហគមន៍មូលដ្ឋានអោយបានល្អ និងជាប្រចាំ។

ជាទីបញ្ចប់នេះ តាំងនាមម្ចាស់គម្រោងវិនិយោគ លើគម្រោងធ្វើអាជីវកម្មរ៉ែលោហៈ របស់ក្រុមហ៊ុន **PHU YANG (CAMBODIA) Co., Ltd.** សន្យានឹងអនុវត្តទៅតាមផែនការដែលខ្លួនបានលើកឡើងស្រាប់នេះ និងគោរពតាមកិច្ចសន្យាជាមួយក្រសួងបរិស្ថានដើម្បីកាត់បន្ថយហេតុប៉ះពាល់ចំពោះបរិស្ថាន សង្គម និងធ្វើអោយហេតុប៉ះពាល់វិជ្ជមានកាន់តែប្រសើរឡើងថែមទៀត។ ហេតុនេះក្រុមហ៊ុនសូមសំណូមពរដល់រាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័នពាក់ព័ន្ធនានាដូចជាក្រសួងបរិស្ថាន និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មេត្តាជួយសំរួល និងបង្កលក្ខណៈងាយស្រួលដល់ការចេញលិខិតអនុញ្ញាតអោយក្រុមហ៊ុនដំណើរការទៅបាន ដោយជោគជ័យស្របតាមផែនការមេដែលបានគ្រោងទុក។

រាជធានីភ្នំពេញ, ថ្ងៃទី...១៥...ខែ...កុម្ភៈ...ឆ្នាំ២០១៣
ក្រុមហ៊ុន ភូ យ៉ាង (ខេមបូឌា) ខូ អិល ធី ឌី
( **PHU YANG (CAMBODIA) Co., Ltd.** )
នាយកក្រុមហ៊ុន

លីន_លុន

រាជធានីភ្នំពេញ, ថ្ងៃទី...១៥...ខែ...កុម្ភៈ...ឆ្នាំ២០១៣
ក្រុមហ៊ុន ហ្គ្រីន អ៊ីនវាយរិនមិន គ្រុប
(**Green Environment Group Co., Ltd.**)
នាយកក្រុមហ៊ុន

មាស សាវឿ

Draft